**សេចក្តីប្រកាសព័ត៌មាន**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

ថ្ងៃទី ១៦ ធ្នូ ឆ្នាំ២០១៩

# កម្មវិធី New Colombo Plan ឆ្នាំ២០២០ ពង្រីកការយល់ដឹងរបស់ជនជាតិអូស្ត្រាលីអំពីប្រទេសកម្ពុជា

តាមរយៈកម្មវិធីNew Colombo Plan រដ្ឋាភិបាលអូស្ត្រាលី នឹងជួយគាំទ្រនិស្សិតថ្នាក់បរិញ្ញាបត្រ អូស្ត្រាលីជាង៥០០នាក់ឲ្យមកស្នាក់នៅ សិក្សា និងបំពេញការងារនៅកម្ពុជា ក្នុងឆ្នាំ២០២០ ខាងមុខ។

លោក Luke Arnold ភារៈធារីស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ថ្លែងថា៖ «យើងទន្ទឹងរង់ចាំស្វាគមន៍ និស្សិតមកពីសាកលវិទ្យាល័យចំនួន១៤ ក្នុងប្រទេសអូស្ត្រាលី ដើម្បីស្វែងយល់បន្ថែមអំពីប្រជាជន និងវប្បធម៌កម្ពុជា»។

និស្សិតទាំងនេះ នឹងធ្វើការជាមួយដៃគូកម្ពុជា ក្នុងការចែករំលែកចំណេះដឹង និងជំនាញ ក្នុងវិស័យនានាដូចជា វិស្វកម្ម ទឹកស្អាត និងអនាម័យ សុខភាព ការអប់រំ និងច្បាប់។

កញ្ញា Bonnie Hammerschmidt ជានិស្សិតក្រោមកម្មវិធី New Colombo Plan មួយរូប ដែលនឹងចំណាយពេលរស់នៅក្នុងប្រទេសកម្ពុជា រយៈពេល៨ខែ។ កញ្ញា Hammerschmidt នឹងសិក្សាផ្នែកចិត្តសាស្ត្រ នៅឯសាកលវិទ្យាល័យកម្ពុជា និងចុះកម្មសិក្សានៅឯអង្គការក្នុងស្រុកមួយឈ្មោះ បន្ទាយស្រី។ អង្គការបន្ទាយស្រី ធ្វើការផ្តោតសំខាន់លើស្ត្រី និងកុមារ។ កញ្ញា Hammerschmidt គឺជាម្នាក់ក្នុងចំណោមនិស្សិតអាហារូបករណ៍ឆ្នើម ១២៥រូប ដែលនឹងទទួលបានបទពិសោធន៍ការងាររយៈពេលវែង និងសិក្សានៅតាមបណ្តាប្រទេសនានាក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

លោក Luke Arnold បន្ថែមថា៖ «អូស្ត្រាលី គឺជាប្រទេសគោលដៅ ក្នុងនាមជាប្រទេសប្រើប្រាស់ភាសាអង់គ្លេស  សម្រាប់ការសិក្សាអប់រំរបស់សិស្សនិស្សិតកម្ពុជា។ ក្នុងនោះ មាននិស្សិតជិតបីពាន់នាក់ បានចុះឈ្មោះចូលរៀននៅស្ថាប័នអប់រំលំដាប់ពិភពលោក ក្នុងប្រទេសអូស្ត្រាលី។ ការណ៍

ដែលនិស្សិតវ័យក្មេងអូស្ត្រាលីជាច្រើន បានជ្រើសរើសយកប្រទេសកម្ពុជាជាគោលដៅសិក្សាក្រោមកម្មវិធី New Colombo Plan នេះ អាចធានាថាទំនាក់ទំនងរវាងប្រទេសទាំងពីរ នឹងទទួលបានការគាំទ្រដោយចំណងដ៏រឹងមាំរវាងប្រជាជនកម្ពុជា និងអូស្ត្រាលី»។

កម្មវិធី New Colombo Plan គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់របស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីពង្រឹងចំណេះដឹងរបស់អូស្ត្រាលី អំពីតំបន់ឥណ្ឌូប៉ាស៊ីហ្វិក តាមរយៈការគាំទ្រដល់និស្សិតអូស្ត្រាលីថ្នាក់បរិញ្ញាបត្រ ឲ្យមកសិក្សា និងចុះកម្មសិក្សានៅក្នុងតំបន់។

និស្សិតអូស្ត្រាលីជាង ៦ម៉ឺននាក់ បានចូលរួមក្នុងកម្មវិធីអាហារូបករណ៍ និងកម្មសិក្សារយៈពេលខ្លីនៃកម្មវិធី New Colombo Plan ចាប់តាំងពីឆ្នាំ២០១៤មក។

ព័ត៌មានបន្ថែមអំពីកម្មវិធី New Colombo Plan សូមចូលទៅកាន់ www.dfat.gov.au/new-colombo-plan

ឬ បណ្តាញសង្គម Twitter @NewColomboPlan

ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ Australian.Embassy.Cambodia@dfat.gov.au